ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សាកលវិទ្យាល័យ អង្គរខេមរា

# ANGKOR KHEMARA UNIVERSITY

## មហាវិទ្យាល័យ

## វិទ្យាសាស្ត្ររបស់អប់រំ

## សិល្បៈ មនុស្សសាស្ត្រ និងភាសា

## ដេប៉ាតឺម៉ង់ ៖ អក្សរសាស្ត្រខ្មែរ

## មុខវិជ្ជា ៖ សិល្បវិទ្យា

## ប្រធានបទ ៖ ស្រីហិតោបទេស ( សង្ក្ខេប )

បង្រៀននិងណែនាំដោយ៖ អនុ.ហ៊្វីន ស៊ីឡូន

រៀបរៀងដោយក្រុមទី៣

សមាជិកក្រុមរួមមាន

១. ឌី ដានី        ៣. អ៊ុំ វណ្ណា

២.ឌី ជីវ័ន្ត        ៤. ចាន់ ស្រី

៥. ឃិន សុភក្តី

និស្សិតអក្សរសាស្ត្រខ្មែរ ជំនាន់ទី១៤ វគ្គទី០១ ឆមាសទី០១ ឆ្នាំទី០៣

សាខាពោធិ៍សាត់

ព.ស២៥៦៧        ឆ្នាំសិក្សា២០២២-២០២៣        គ.ស ២០២៣

# **អារម្ភកថា**

**ហិតោបទេស** មកពីពាក្យ **ហិត** (ប្រយោជន៍) +**ឧបទេស** (ការទូន្មាន) សំដៅដល់អត្ថបទពន្យល់ឱ្យស្គាល់នូវប្រយោជន៍ ដឹកនាំជនានុជនឱ្យរកឃើញផ្លូវនៃសេចក្តីសុខក្នុងលោកិយយើងនេះ ឬអាចនិយាយម្យ៉ាងទៀតថាជាការប្រៀនប្រដៅជនានុជនទាំងឡាយឱ្យមានសីលធម៌នៅក្នុងជីវភាពរស់នៅ និងឆ្ពោះទៅរកភាពរីកចម្រើននៅក្នុងដំណើរជីវិត។ សៀវភៅស្រីហិតោបទេស ដែលប្រែចេញពីភាសាសំស្ក្រឹតដោយ **ព្រះកិត្តិវិរិយបណ្ឌិតោ ប៉ាង ខាត់** ដែលបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៤៩ ជាអត្ថបទដែលមានជម្រៅខាងពាក្យពេចន៍ និងឃ្លាល្បះ ដ្បិតមានពាក្យពេចន៍ជាច្រើនប្រើប្រាស់ជាភាសាសំស្ក្រឹត។

នៅក្នុងកិច្ចការស្រាវជ្រាវមួយនេះគឺមានលើពីត្រង់ភាគ "ឈ្មោះសង្គ្រាម" ដែលបង្ហាញពីភាពអង់អាចក្នុងការធ្វើចម្បាំងរវាង ស្តេចហង្ស និងស្តេចក្ងោក ព្រមទាំងបានផ្តល់ជាគិតល្អៗដល់មិត្តអ្នកអានគ្រប់រូបសម្រាប់យកទុកជាគតិអប់រំ និងយកទៅគិតពិចារណា។

ស្នាដៃដ៏តូចមួយនេះ ទោះជាមានការខិតខំពិនិត្យពិច័យយ៉ាងណាក៏ដោយ ពួកខ្ញុំជឿជាក់ថាកំហុសនៅតែកើតមានឡើងជាក់ជាពុំខាន។ ដូច្នេះក្រុមយើងខ្ញុំទាំងអស់គ្នាសូមអភ័យទោសពីសំណាក់ អ្នកសិក្សាទូទៅ និង ពិសេសលោកគ្រូ អនុ. ហ៊ួន ស៊ីឡូន ដែលបង្រៀនលើមុខវិជ្ជា សិល្បវិទ្យាមួយនេះ នូវកំហុសឆ្គងលើផ្នែកអក្ខរាវិរុទ្ធ ឬពាក្យពេចន៍ជាដើមដដែលកើតមានក្នុងកិច្ចការស្រាវជ្រាវមួយនេះ។ រាល់កំហុសឆ្គងទាំងឡាយក្រុមយើងខ្ញុំចាំទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនាពីមិត្តនិស្សិត និងលោកគ្រូ។

*តាលោសែនជ័យ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣*

# សេចក្តីថ្លែងអំណរគុណ

ទន្ទឹមនឹងការកកើតនូវស្នាដៃឡើងបានជាលទ្ធផលនេះខ្ញុំបាទសូមសម្តែងនូវអំណាគុណជាអនេកប្រការចំពោះ ៖

លោកឪពុក អ្នកម្តាយនៃខ្ញុំទាំងឡាយជាបុព្វាចារ្យនឹងជាព្រះអរហន្តដ៏ប្រសើររបស់ខ្ញុំបាទដែលលោកបានផ្តល់នៅកំណើត ហើយចិញ្ចឹមបីបាច់ថែរក្សាដោយព្រហ្មវិហារធម៌។ ជានិច្ចកាលលោក តែងតែណែនាំចង់ឲ្យក្លាយជាគ្រាប់ពូជដ៏មានតម្លៃមួយ។

លោកគ្រូ អ្នកគ្រូទាំងអស់តាំងពីថ្នាក់បឋមសិក្សារហូតមកដែលលោកបានបង្ហាត់បង្រៀនឲ្យខ្ញុំបាទនូវទ្រព្យសម្បត្តិដែលមិនអាចកាត់ថ្លៃបានពោលគឺចំណេះវិជ្ជា ព្រមទាំងសីលធម៌ សុជីវធម៌ ក្នុងសង្គមធ្វើឲ្យក្លាយជាធនធានដ៏មានតម្លៃមួយសម្រាប់សង្គមជាតិ។

បណ្ឌិត **នូ ចាន់សុភី** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអង្គរខេមរា និងគណៈគ្រប់ គ្រងនៃសាកលវិទ្យាល័យអង្គរខេមរាទាំងអស់ ធ្វើឲ្យខ្ញុំបានទទួលបានចំណេះដឹងដ៏មានតម្លៃ សម្រាប់ជួយខ្លួនឯង គ្រួសារ និងសង្គមជាតិបានមួយចំណែក។

សាស្ត្រាចារ្យក្នុងដេប៉ាតឺម៉ង់ អក្សរសាស្ត្រខ្មែរនៃសាកលវិទ្យាល័យអង្គរខេមរាទាំងអស់ដែលបានខិតខំប្រិតប្រៀនតម្រែតម្រង់នៅមុខវិជ្ជាទាំងឡាយក្នុងជំនាញអក្សរសាស្ត្រខ្មែរញ៉ាំងឲ្យខ្ញុំបាទ ទទួលនូវចំណេះដឹងយ៉ាងស្រួចស្រាល់លើជំនាញរបស់ខ្ញុំ។ ជាពិសេសសូមអរគុណជាអនេក ចំពោះ សាស្ត្រាចារ្យអនុបណ្ឌិត **ហ៊្វន ស៊ីឡុន** ដែលបង្រៀនលើមុខវិជ្ជា***សិល្បវិទ្យា*** ដែលបានណែនាំកែតម្រូវលើកិច្ចការស្រាវជ្រាវមួយនេះ។

# ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនចំពោះ៖

- វិញ្ញាណក្ខន្ធបុព្វបុរសខ្មែរគ្រប់រូបដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារជាតិមាតុភូមិ។
- វិញ្ញាណក្ខន្ធកវី បណ្ឌិត អ្នកនិពន្ធ អ្នកប្រាជ្ញខ្មែរគ្រប់ជំនាន់។ ដែលបានខិតខំថែរក្សាអក្សរសាស្ត្រជាតិឱ្យរីកចម្រើនគង់វង្សរហូតមកដល់សព្វថ្ងៃ។
- វិញ្ញាណក្ខន្ធសម្តេចព្រះសង្ឃរាជ ជួន ណាត ដែលព្រះអង្គបាន បន្សល់ស្នាដៃដ៏វិសេសវិសាលសម្រាប់កូនខ្មែរគ្រប់ជំនាន់នោះគឺ សៀវភៅវចនានុក្រមខ្មែរ។
- វិញ្ញាណក្ខន្ធនៃបុព្វការីជនរបស់ខ្ញុំទាំងអស់។

សូមជួយទ្រទ្រង់វិស័យអក្សរសាស្ត្រជាតិឱ្យកាន់តែរីកចម្រើនជានិច្ចនិរន្តរ៍។

# សេចក្ដីផ្ដើម

ក្នុងនាមខ្ញុំជាសិស្សនិស្សិតបានទទួលការអនុញ្ញាតពីលោកគ្រូ **ហ៊ួន ស៊ីឡូន សាស្ត្រាចារ្យ** មុខវិជ្ជាសិល្បវិទ្យា លោកបានឱ្យយើងខ្ញុំចងក្រងសរសេរពីសៀវភៅស្រីហិតោបទេ ត្រង់ភាគ សង្គ្រាម ដើម្បីថែរក្សាការពារកេរដំណែលវប្បធម៌ អក្សរសាស្ត្រជាតិ និងបំពេញសេចក្ដីត្រូវការរបស់ប្រិយមត្តិ មិត្តអ្នកអានសិស្សនិស្សិត។ ក្នុងការចងក្រងឡើងវិញនេះ យើងខ្ញុំបានរក្សាអត្ថន័យ អត្ថរស ខ្លឹមសារ និងឃ្លោងឃ្លាមិនបានទាំងស្រុងនោះទេ គឺបានត្រឹមតែសង្ខេបតែប៉ុណ្ណោះ។

នៅក្នុងកិច្ចការមួយនេះ យើងខ្ញុំរីករាយនឹងរង់ចាំទទួលនូវការរិះគន់កែលំអក្នុងន័យស្ថាបនាពីសំណាក់ប្រិយមិត្ត មិត្តសិស្សនិស្សិត និងលោកគ្រូជាទគោរព ដើម្បីធ្វើឱ្យការចងក្រងរបស់ក្រុមយើងលើកក្រោយកាន់តែពិសេសថែមទៀត។

## មាតិកា


**ជំពូកទី១ ទិដ្ឋភាពសង្គម............................................................................ ទំព័រទី ០១-០២**

១.ឥទ្ធិពលសង្គម ...............................................

២.ទម្រង់អក្សរសិល្ប៍ ..........................................

ក.ប្រភពរឿង .................................................

ខ.ប្រភេទរឿង ................................................

គ.កាលបរិច្ឆេទ ...............................................

ឃ.ចលនា .....................................................

៣.អ្នកនិពន្ធនិងស្នាដៃ...........................................

ក.ប្រវត្តិអ្នកនិពន្ធ............................................

ខ.ស្នាដៃ .......................................................

គ.បញ្ចូលក្នុងកម្មវិធីសិក្សា................................

**ជំពូកទី២ ទិដ្ឋភាពស្នាដៃ............................................................................ ទំព័រទី ០៣-១៣**

I. វិភាគអត្ថន័យរឿង...........................................

ក.សង្ខេបរឿង ................................................

ខ.ប្រធានរឿង ................................................

គ.មូលបញ្ហារឿង ............................................

ឃ.ឧត្តមគតិរឿង ............................................

ង.វិភាគតួអង្គ ................................................

II. វិភាគអត្ថរូប ................................................

១.និពន្ធរូប ....................................................

២.បច្ចេករូប ...................................................

III. វិភាគអត្ថរស ...............................................

១.សោភ័ណរស...............................................

២.ទារណរស ..................................................

៣.វិសិដ្ឋរស ....................................................

៤.ហាសរស....................................................

៥.តថរស .......................................................

៦.សង្គមរស ...................................................

៧.កុសលរស ..................................................

**ជំពូកទី៣ ........................................................................................................ទំព័រទី ១៣**

១.សេចក្តីសន្និដ្ឋាន............................................

២.ប្រភពឯសារ( ឯកសាយោង ) ..........................

# ជំពូកទី១ និដ្ឋភាពសង្គម

## ១. ឥទ្ធិពលសង្គម

តាមរយៈស្នាដៃនៃរឿងស្រីហិតោបទេសរបស់បណ្ឌិត នារាយណៈ បានបង្ហាញពីឥទ្ធិពលសង្គមនាសម័យដែលគ្រប់គ្រងដោយស្តេច ស្តេចជាអ្នកចាត់ចែងលើគ្រប់កិច្ចការទាំងឡាយ។ព្រមទាំងឆ្លុះបញ្ចាំងពីការវាទទីជរាប តាមវិធីផ្សេងៗ ពិសេសការធ្វើសង្គ្រាមដើម្បីពង្រីកឥទ្ធិពល។

## ២. ទម្រង់អក្សរសិល្ប៍

**ក. ប្រភពរឿង៖** រឿងនេះមានប្រភពមកពីប្រទេសឥណ្ឌា ដែលជាស្នាដៃរបស់បណ្ឌិត **នារាយណៈ** ដកស្រង់ចេញពីគម្ពីរដើមឈ្មោះបញ្ចាតន្ត្រៈ និងគម្ពីរផ្សេងៗទៀត។

**ខ. ប្រភេទរឿង៖** បើពិនិត្យតាមដំណើររឿងយើងឃើញថា រឿងនេះជាប្រភេទរឿងនិទានកថាសត្វ។

**គ. កាលបរិច្ឆេទ៖** រវាងសតវត្សរ៍ទី១០ នៃពុទ្ធសករាជ (សតវត្សរ៍ទី៥ គ.ស)។

**ឃ. ចលនា៖** អក្សរសិល្ប៍បរទេសនិយម។

## ៣. អ្នកនិពន្ធនិងស្នាដៃ

(ជីវប្រវត្តិ និងស្នាដៃ)

ព្រះមហាវិរិយបណ្ឌិតតោ ប៉ាង ខាត់ កុមារខាត់កើតរវាងឆ្នាំ១៩១០ នៅភ្នំដិល ស្រុកបាជាយ ក្នុងខេត្តកំពុងចាម។ បិតានាម ប៉ាង និងមាតានាម អុង។ ដល់ធំដឹងក្តីហើយកុមារនេះបានបួសរៀនក្នុងសំណាក់ពុទ្ធសាសនាហើយបានប្រឡងជាប់ចូលរៀននៅសាលាបាលីជាន់ខ្ពស់ ព្រះភិក្ខុប៉ាង ខាត់ប្រឡងជាប់ចូលរៀនជាសាស្ត្រាចារ្យភាសាបារាំង ដោយបានពិន្ទុល្អទៀតផង ដូចសេចក្តីបញ្ជាក់ក្នុងអត្ថបទលោកចុះផ្សាយក្នុងទស្សនាវដ្តីពុទ្ធសាសនា និងអក្សរសាស្ត្រខ្មែរ "មិត្តសាលាបាលី" ឆ្នាំទី២ លេខ១ ខែមករា ១៩៥១ ទំព័រ២៦ ថា "កាលខ្ញុំប្រឡងចូលរៀនសាលាបាលីជាន់ខ្ពស់ហើយខ្ញុំត្រូវប្រឡងចូលរៀនភាសាបារាំង ខាងធ្វើគ្រូទៀត កាលនោះខ្ញុំមានសំណាងបានពិន្ទុច្រើនជាងគេ"។ ពេលដែលភិក្ខុ ប៉ាង ខាត់សិក្សាក្នុងក្រុងភ្នំពេញ លោកសំណាក់នៅ វត្តឧណ្ណាលោម ក្នុងកុដិព្រះពោធិវង្ស ហួត តាត ហើយលោកជាសិស្ស គណៈព្រះពោធិវង្ស។ បន្ទាប់មកបានចប់សិក្សានៅសាលាបាលីជាន់ខ្ពស់ ភិក្ខុប៉ាង ខាត់បានធ្វើជាសាស្ត្រាចារ្យភាសាបាលី ចាដំបូងនៅវត្ត ប្រាង្គក្នុងស្រុកឧដុង្គ។

តួនាទីឧត្តមសិក្សា ភិក្ខុ ប៉ាង ខាត់ ធ្វើជាសាស្ត្រាចារ្យភាសាសំស្ក្រឹត និង ភាសាបាលៅ នៅសាកលវិទ្យាល័យព្រះសីហនុរាជភ្នំពេញ។ ទន្ទឹមនឹងភារៈកិច្ចនៅសាកលវិទ្យាល័យ ព្រះសីហនុ ភិក្ខុ ប៉ាង ខាត់ បានមកបង្រៀនការសិក្សាអក្សរថ្ម និង ខ្មែរបុរាណ ហើយនិងប្រវត្តិសាសនាឥណ្ឌា-ខ្មែរ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ភក្ខុប៉ាងខាត់បានបង្រៀភាសាបាលីជាច្រើន នៅសាលាបាលីជាន់ខ្ពស់នៅភ្នំពេញ ដែលមានព្រះពោធិវង្ស ហួត តាតជាចាងហ្វាង សាសាបាលីជាន់ខ្ពស់និងជាអធិបតីក្រុមជំនុំ ព្រះត្រៃបិដក គឺជាអតីតគ្រូអាចារ្យលោក។ បន្ទាប់មកលោកបានបង្រៀន ភាសាសំស្ក្រឹត នៅសាកលវិទ្យាល័យព្រះសីហនុរាជក្រុងភ្នំពេញ រហូតដល់ឆ្នាំ១៩៧៥។

ភិក្ខុ ប៉ាង ខាត់ បានបង្រៀននៅ មហាវិទ្យាល័យអក្សរសាស្ត្រ និង មនុស្សសាស្ត្រ ភ្នំពេញរហូតដល់ឆ្នាំ១៩៧៥នៅ មុខវិជ្ជា២គឺ អក្សរថ្មី និងភាសាខ្មែរបុរាណ ខ្មែរកណ្តាល សម្រាប់និស្សិតរៀនយក សញ្ញាបត្រ សិក្សាជាន់ខ្ពស់ផ្នែក វេយ្យាករណ៍និងនិរុត្តិវិទ្យា។ ប្រវត្តិសាស្ត្រសាសនា ឥណ្ឌា-ខ្មែរ សម្រាប់និស្សិតរៀនយកសញ្ញាបត្រផ្នែកវប្បធម៌ និង អរិយធម៌ខ្មែរ។ នេះជាកម្មវិធីដែលភិក្ខុ ប៉ាង ខាត់បង្រៀនដល់និស្សិតយកសញ្ញាបត្រផ្នែកវេយ្យាករណ៍ និងនិរុត្តិវិទ្យាមាន៖

ក.ពាក្យសំស្ក្រឹត ក្នុងអត្ថបទ "ទសជាតក"

ខ.ពាក្យបាលី ក្នុងអត្ថបទ "ទសជាតក"

គ.ខ្មែរបុរាណគឺសិក្សាអំពីឯកសារជា ភាសាខ្មែរបុរាណនិងការវិវត្តន៍ នៃភាសានេះតាំងពីស.តទី៧-១៨-១៩

ភិក្ខុ ប៉ាង ខាត់ ជាអ្នកប្រាជ្ញជាតិម្នាក់ ដែលយើងមិនអាចបំភ្លេចបាន។ លោកបានបន្សល់ទុកស្នាដៃជាច្រើនដែលទុកជាកេរ្តិ៍ ពិសេសគឺសៀវភៅ ស្រីហិតោបទេស៤ភាគ និងប្រវត្តិពុទ្ធសាសនាកម្ពុជា( ជាភាសាខ្មែរ និងភាសាបារាំង)។ ភិក្ខុប៉ាង ខាត់បានសរសេរអត្ថបទជាច្រើនពន្យល់ពុទ្ធមាមកជនថា "ព្រះពុទ្ធសាសនា" គឺជាវិទ្យាសាស្ត្រនិងបង្ហាញពីតម្លៃសាកលជាឫសគល់ពិតនៃពុទ្ធសាសនា។

ភិក្ខុ ប៉ាង ខាត់ជាសង្ឃជឿនលឿននិយម មានគំនិតទូលំទូលាយដែលសិស្សអាចជជែកពិភាក្សា ពិគ្រោះដោះស្រាយ រិះគន់ស្ថាបនា ប្តូរយោបល់បាន។ នៅសម័យ សាធារណរដ្ឋខ្មែរ១៩៧០-១៩៧៥ ភិក្ខុ ប៉ាង ខាត់មានតួនាទីយ៉ាងសកម្ម ក្នុងនយោបាយជាតិ សម័យនោះគឺលោកចូលប្រជុំជាមួយ គណៈរដ្ឋមន្ត្រីជាច្រើនលើក ហើយលោកបានចេញឃោសនាការពារនយោបាយ រដ្ឋដរាបរបបសាធារណរដ្ឋខ្មែរ។ នៅសម័យនោះលោកមែងទេសនាវិលែកទុកគ្រួសារយុទ្ធជន ដែលបានបូជាជីវិតក្នុងសមរភូមិ។ ភិក្ខុ ប៉ាង ខាត់បានសុគតនៅឆ្នាំ១៩៧៥។

**ស្រីហិតោបទេសបានបញ្ចូលក្នុងកម្មវិធីសិក្សា** ( *ពុទ្ធសាសនបណ្ឌិត ព.ស២៥៣៨*)

## ជំពូកទី២ ទិដ្ឋភាពស្នាដៃ

## សង្ខេបរឿង(សង្គ្រាម)

ក្នុងពេលដែលចាប់ផ្ដើមរឿងតទៅទៀត ព្រះរាជបុត្រទាំងឡាយមានព្រះរាជបន្ទូលត្រាស់ថា៖ "បពិត្រលោកមហាបណ្ឌិតជាទីគោរពយើងទាំងអស់គ្នាជារាជបុត្រត្រូវការស្ដាប់រឿងសង្គ្រាមតទៅទៀត"។ លោកមហាបណ្ឌិតក្រាបទូលថា៖ "បើដូច្នោះព្រះទូលបង្គំនឹងបរិយាយរឿងរ៉ាវដែលទ្រង់ទាំងឡាយសព្វព្រះទ័យដូចតទៅនេះ។

១.ក្នុងសង្គ្រាមរវាសស្ដេចហង្សនិងស្ដេចក្អែក ដែលមានកម្លាំងក្លៀវក្លាស្មើគ្នាហង្សត្រូវក្អែកនៅសំណាក់ក្អែកជាសត្រូវមកលួងធ្វើឱ្យស្និទ្ធស្នាលបោកបញ្ឆោតបាន។

ព្រះរាជបុត្រទាំងឡាយត្រាស់សួរថា "ចុះរឿងនោះតើមានដំណើរ ដើមហេតុដូចម្ដេច?"។ លោកមហាបណ្ឌិតក៏ចាប់ផ្ដើមពណ៌នា រឿងនោះទូលថ្វាយដូចសេចក្ដីតទៅថា

## រឿង ហង្ស និងក្អែក

នៅក្នុងប្រទេសមួយមានបឹងមួយជាទីអាស្រ័យនៃស្ដេចហង្សត្រូវបានបក្សីរកស៊ីលើផ្ទៃទឹកព្រមព្រៀងគ្នាអភិសេកហង្សនោះឱ្យធ្វើជាស្ដេចហង្ស ក្នុងស្ដេចហង្សកំពុងសម្រាក់លើរាជ្យបល្ល័ង្កដែលជាស្លឹកឈូកមានបរិវារចោមរោមគ្រៀបគ្រា។ ហើយពេលនោះមានសត្វកុកមួយក្បាល ត្រឡប់ពីបរទេស។ ស្ដេចហង្សសួរថា "នែ៎កុក!អ្នកឯងទើបមកដល់ចូលនិយាយរឿងអ្វីប្លែកប្រាប់យើងបន្ដិចមើល!"។ កុកឆ្លើយប្រាប់ថា៖ "បពិត្រព្រះអង្គ! មានរឿងប្លែកចម្លែកអស្ចារ្យណាស់" ហេតុនេះហើយទើបទូលបង្គំវិលត្រឡប់យ៉ាងរហ័ស ដើម្បីជម្រាបដំណឹងនេះ ពេលទូលបង្គំនៅប្រទេសនោះមានភ្នំមួយជាទីអាស្រ័យនៃស្ដេចក្អែក។កាលនោះទូបង្គំស្វែងរកចំណីនៅក្នុងព្រៃដែលត្រូវភ្លើងឆេះមួយកន្លែងទូលបង្គំបានជួបបរិវានឹងស្ដេចក្អែក។ បរិវាស្ដេចក្អែកនោះសួរទូលបង្គំថា "អ្នកមានការអ្វី? មានការអ្វី?ទៅណាមកណាបានជាមកទីនេះ? ពេលនោះទូលបង្គំប្រាប់វិញថា "ខ្ញុំជាបរិវាស្ដេចហង្សដែលជាស្ដេចចក្រពត្តិ ខ្ញុំមកទីនេះដើម្បីរកមើលក្រុងនៃប្រទេសទាំងឡាយ"។ បក្សីជាបរិវាស្ដេចក្អែក ស្ដាប់ពាក្យទូលបង្គំរួចសួរថា "ចុះប្រទេសទាំងពីនេះគឺប្រទេសរបស់អ្នកនិងប្រទេសរបស់ ខ្ញុំតើប្រទេសណាមួយគ្រាន់បើជាងប្រទេសណា ស្ដេចណាគ្រាន់បើជាស្ដេចណា"។ ទូលបង្គំឆ្លើយប្រាប់ថា "អ៎ា! ដូចម្ដេចក៏ហ៊ានសួរដូច្នោះ? ខុសគ្នាឆ្ងាយណាស់! ប្រទេសដែលដឹកនាំដោយស្ដេចរបស់ដូចជាស្ថានសួគ៌ ស្ដេចហង្សទុកដូចជាព្រះឥន្ទ្រាធិរាជ ជាស្ដេចស្ថានសួគ៌ ឯនៅទីនេះដ៏ក្រៀមក្រោះឥតជីវជាតិមានតែដីត្រូវភ្លើងឆេះរលីងថេងយ៉ាងនេះរស់នៅម្ដេចកើត។ មក! ចូលទៅរស់នៅក្នុងប្រទេសខ្ញុំទៅ"។ បក្សីដែលជាបរិវាស្ដេចក្អែកក៏ក្រេវក្រោធខឹងក្រៃលែង ក៏សួរទៀតថា "ស្ដេចហង្សជាស្ដេចអ្នកឯងនោះ បានអ្នកណាលើកតម្កើងធ្វើជាស្ដេច?"។ ព្រមទាំងចេរទូលបង្គំថា "នែ៎ អាគម្រកអាកុកចង្រៃ! អាឯងចូលមកដល់ទឹកដីហើយម្ដេចអាឯងប្រហើនហ៊ានមើលងាយដល់ម្ចាស់យើងផង! យើងអត់ទោសឱ្យឯងមិនបានទេ" សត្វក្អែកទាំងឡាយចូលចោមរោមចឹកទូលបង្គំ ប៉ងសម្លាប់ ហើយស្រែចេរទាំងកំហឹងថា "នែ៎អាគម្រកល្ងង់ចង្រៃ! ហង្សជាស្ដេចឯងកំសាកញីទេ

ឥតមានកម្លាំងអំណាចអ្វីគ្រប់គ្រងដែនដីនេះទេ ព្រោះស្តេចដែលខ្សោយជរាបមិនអាចគ្រប់គ្រងរាជនៅក្នុងកណ្តាប់ដៃបានឡើយ បើដូច្នោះធ្វើដូច្នោះ តើធ្វើដូចម្តេចស្តេចអាឯងអាចគ្រប់គ្រងលោកនេះបានរាជស្តេចអាឯង? នោះវាធំយ៉ាងណាទៅ? រីឯខ្លួនអាឯងនេះដូចកង្កែបដែលមិនដែលចេញពីអណ្តូងសោះ បើម្ល៉ឹងៗតើអាឯងម្តេចហ៊ានមើលងាយយើង ឱ្យយើងចូលទៅស្វាមីភក្តិស្តេចអាឯងម្តេចកើត? យើ អាឯងអីកោងម្ល៉េះ អាឯងស្តាប់មើល!

ក្រោយពីក្ងោកនិយាយពីរឿងដំរីចប់ហើយពេលនោះកុកអួតប្រាប់សត្វក្ងោកទាំងនោះថាស្តេចហង្សជាម្ចាស់យើងមានតេជានុភាពមានសក្តានុភាព ព្រមទាំងមានសមត្ថភាពគួរនឹងមានសោយរាជ្យគ្រប់គ្រងត្រៃភពនេះ។ កាលនោះសត្វក្ងោកចេរកុកថានែ អាប្រហើន បើគ្រាន់បើណាស់ម្តេចអាឯងមកកាន់ទីនេះធ្វើអ្វី ចេរហើយចាប់កុកទៅសំណាក់តែម្តង ហើយបរិវាទាំងឡាយទូលស្តេចថា "បពិត្រព្រះអង្គ សូមព្រះអង្គជ្រាបថាកុកប្រហើននេះមកកាន់ប្រទេសយើងហ៊ានប្រមាថមកកាន់ចេស្តា ស្តេចក្ងោកក៏សួរទៅកាន់កុកថា ជាអ្វីមកពីណា បរិវាក៏ប្រាប់ថាកុកជាចារបុរសថាជាចារបុរសស្តេចហង្ស។ ចំណែកឯត្មាតជារដ្ឋមន្ត្រីថា អ្នកណាជារដ្ឋមន្ត្រីនៅទីនោះ កុកនិយាយថាប្រវឹកជារដ្ឋមន្ត្រីនៅទីនោះដែលជាអ្នកមានចំណេះដឹងវិទ្យាសាស្ត្រ។ ពេលនោះផងដែលសេកជារដ្ឋមន្ត្រីនិយាយថាប្រទេសនោះជារដ្ឋតូចទេ ហើយស្ថិតក្នុងអាណាចក្ររបស់ព្រះអង្គដូចនេះ ដូចនេះប្រទេសទាំងឡាយនេះ ស្ថិតក្នុងអាធិបតេយ្យភាពរបស់ព្រះអង្គទាំងអស់ ពេលនោះក្ងោកនិយាយចាក់បណ្តោយតាមសេកដែរ ពេលនោះសត្វកុកនិយាយថាគ្រាន់តែនិយាយហើយបានស្ថិតអធិបតេយ្យភាព ដូចមាត់នោះខ្ញុំក៏ចេះនិយាយដែលថាប្រទេសរបស់ស្តេចក្ងោកក៏ឋិតនៅក្នុងជរាបស្តេចហង្សដែរ សេកសួរកុកថា ធ្វើម្តេចនឹងសម្រេចប្រស្នានេះបាន? កុកថាមានតែសង្គ្រាម ហើយស្តេចក្ងោកនិយាយប្រាប់កុកថា ឯងត្រឡប់ទៅប្រាប់ម្ចាស់វិញថា ឱ្យរៀបចំកម្លាំងទ័ពត្រៀមចាំចុះ ពេលនោះកុកឱ្យក្ងោកបញ្ចូលរាជទូតទៅចរចារសិនចុះ ស្តេចក្ងោកក៏ព្រឹក្សារ ជាមួយមន្ត្រីថានឹងត្រូវតាំងនរណាជារាជទូត ព្រោះរាជទូតគួរចេះកិច្ចការនឹងគុណសម្បត្តិ ពេលនោះត្មាតថាបុគ្គលមានលក្ខណៈ ដូច្នេះមានច្រើនណាស់ គួរតាំងព្រាហ្មណ៍ចរចារ ព្រោះព្រាហ្មណ៍ធ្វើឱ្យចម្រើន ដល់ព្រះរាជាមិនចង់បានទ្រព្យសម្បត្តិ មិនខុសពីហនុមានការពារព្រះរាមនោះទេ ពេលនោះស្តេចក្ងោកបានចាប់ឱ្យសេកទៅជាមួយកុកឱ្យប្រាប់ហង្សថាយើងរៀបកងទ័ពច្បាំងហើយ។

កុកបានមកដល់ប្រទេសរបស់ខ្លួន ហើយបានប្រាប់ដំណឹងដល់ហង្សពេលនោះសត្វប្រវឹកដែលជាប្រធានរដ្ឋមន្ត្រីសើច ហើយនិយាយទៅកាន់ស្តេចហង្សថាកុកធ្វើដំណើរទៅបរទេស ពេលត្រឡប់មកវិញចេះចាត់ចែងរាជការតាមវិធីល្ងង់។ បន្ទាប់មកទៀតហង្សនិងសត្វប្រវឹកបានទៅទីស្ងាត់តែពីនាក់ សត្វប្រវឹកនិយាយទៅកាន់ហង្សថាហេតុដែលកុកធ្វើឱ្យកើតឡើងនេះប្រហែលជាមានបរិវារយើងខ្លះជាអ្នកញុះញង់ឱ្យធ្វើទេដឹង ពេលនោះស្តេចហង្សនិយាយរឿងនេះធ្លាប់មានដែលតែចាំស៊ើបអង្កេតពេលក្រោយ ខណៈនោះប្រវឹកនិយាយទៅកាន់ហង្សថាគួរបញ្ចូលចារបុរសឱ្យចូលទៅដល់ទីតាំងរបស់សត្រូវឱ្យដឹងថាសត្រូវមានកម្លាំងឬឥតកម្លាំងជាមុនសិន។ ទើបចុងក្រោយស្តេចហង្សនិងប្រវឹកសម្រេចឱ្យកុកធ្វើជាចារបុរសនិងមានកុកមួយទៀតទៅកាន់នគរក្ងោកនោះដែលលុះពេលដឹងព្រឹត្តការណ៍របស់សត្រូវហើយត្រូវទុកកុកឱ្យនៅទីនោះ ហើយត្រូវឱ្យអ្នកទីពីរជាជំនួយការនោះនាំយកការសម្ងាត់ដែលស៊ើបបានមកប្រាប់ដល់ស្តេចហង្សតែត្រូវលាក់ការសម្ងាត់បំផុតស្របនោះដែរស្រាប់តែអ្នកយាមទ្វាមកប្រាប់ថាមានសេកនៅចាំមាត់ទ្វាពេលនោះ ប្រវឹកឱ្យសេនានាំសេកទៅរងចាំនៅសាលាប្រជុំមួយស្របកទើបនាំខ្លួនមកជួបនឹង

ព្រះអង្គ។ ពេលនោះស្ដេចហង្សតក់ស្លុតយ៉ាងខ្លាំងបាននិយាយថា "គួរឱ្យបារម្ភណាស់ក្រៃ សង្គ្រាមផ្ទុះឡើង" ប្រវឹកឆ្លើយថាការធ្វើសង្គ្រាមភ្លាមៗមិនមែនជាការល្អទេ តែបើសង្គ្រាមពិតកើតឡើងហើយគេចមិនរួចទេត្រូវច្បាំងតទល់។ ដូចនេះត្រូវយកចិត្តទុកដាក់រក្សាសេកជារាជទូតឱ្យនៅក្នុងប្រទេសយើងសិន កុំអាលលែងទៅចាំយើងក៏សាងបន្ទាយការពារសិន។ ហើយពេលនោះស្ដេចពិភាក្សារជាមួយប្រវឹកដោយបានតែងតាំងសត្វក្រសារជាអ្នកក៏សាងបន្ទាយមានគូទឹកនឹងបង្កប់ឱ្យធ្វើឃ្លាំងសន្សំស្បៀងឱ្យបានគ្រប់គ្រាន់កុំឱ្យខ្វះខាត។ ស្របពេលនោះទៀតអ្នកយាមទ្វារប្រាប់ស្ដេចហង្សថាមានក្អែកមកពីបរទេសនិងបរិវាចង់ចូលជួបដោយយល់ថា ជាអ្នកមានបទពិសោធន៍ច្រើន តែប្រវឹកនិយាយរំឭក ស្ដេចហង្សដែលថាក្អែកជាសត្វដីគោក វាជាសត្រូវនិងយើងដែរតែហង្សមិនជឿហើយឱ្យក្អែកចូលជួប។ ពេលនោះប្រវឹកនិយាយទៅកាន់ស្ដេចហង្សថា យើងបញ្ជូលចារបុរសទៅហើយបន្ទាយក៏សាងរួចដែរ គួរតែឱ្យសេកចូលមកសាក់សួរហើយចាំលែងទៅវិញ។ គ្រានោះក្អែក និងសេកបានចូលគាល់ស្ដេចហង្សក្នុងពេលតែមួយ សេកក៏បានទូលស្ដេចហង្សថា "បពិត្រព្រះអង្គ! ស្ដេចក្ងោករបស់ទូលបង្គំ ដែលព្រះបាទទ្រដោយផ្កាឈូករីកភ្លឺដោយកែវមណី ដែលប្រដាប់ដោយម្កុដនៃស្ដេចសាមន្តរាជដែលឱនសិរិសាគោរពត្រាស់បង្គាប់មកលោកថា "បើចង់មានជីវិតរស់នៅ ឬប្រាថ្នាឥស្សរយសចូលប្រញាប់ទៅថ្វាបង្គំចំពោះប្របាទយើងបើមិនដូច្នោះទេ ចូររត់គេចទៅកាន់ទីដទៃឱ្យឆាប់ៗទៅ!"។ ពេលនោះស្ដេចហង្សខឹងក៏និយាយឱ្យគេចាប់ច្របាច់កសេក។ ពេលនោះក្អែកក៏ស្ទុះចូលបម្រុងនឹងចាប់សេកខណៈនោះប្រវឹកបានសម្របសម្រួលហង្សនិងក្អែកកុំអាល់ខឹងក្រោធពេលនោះសេកក៏បានលាទៅវិញដោយសត្វប្រវឹកជូនដំណើរ ព្រមទាំងឱ្យរង្វាន់ជាមាសថែមទៀតផង។

និយាយពីស្ដេចក្ងោកវិញ នៅពេលដែលឃើញសេកក៏សួរអំពីប្រទេសតរបស់ហង្សពេលនោះសេកប្រាប់ថា "បពិត្រព្រះអង្គ! បើពេលឱ្យខ្លី ត្រូវតែរៀបចំធ្វើសង្គ្រាម ពីឥឡូវនេះព្រោះប្រទេស ព្រោះប្រទេសនេះទុកដូចជាស្ថានសួគ៌ ចំណែកស្ដេចហង្សប្រៀបដូចជាម្ចាស់ស្ថានសួគ៌ តើធ្វើម្ដេចនឹងពណ៌នាបាន?" ខណៈនោះស្ដេចក្ងោកបានប្រជុំមន្ត្រីធំៗដើម្បីរៀបចំធ្វើសង្គ្រាម ពេលនោះត្មាតបាននិយាយទៅកាន់ស្ដេចក្ងោកថា ការធ្វើសង្គ្រាមបើធ្វើដោយមិនមែនជាការល្អទេ ពេលនោះក្ងោកឱ្យមន្ត្រីដើរត្រួតមើលកងទ័ពព្រមទាំងអាវុធនិងស្បៀង ហើយហៅហោរាឱ្យគន់គូមើល ថ្ងៃដែលល្អសម្រាប់ចេញទ័ពច្បាំង។ ហើយពេលនោះត្មាតនិយាយថាការចេលទ័ពដោយរួសរាន់មិនគួរគប្បីទេពេលនោះស្ដេចក្ងោកបានបន្ទោសត្មាតថាកុំមិនបង្អាក់សេចក្ដីក្លាហានរបស់ខ្លួន។ ខណៈនោះត្មាតបានរកវិធីសាស្ត្រល្អក្នុងការធ្វើសង្គាមដើម្បីទទួលបានជោគជ័យស្ដេចក្ងោកស្ដាប់ហើយទាស់ចិត្ត ក៏បង្គាប់យាត្រាចេញទៅតាមហោរាកំណត់។ ឯចារបុរសហង្សដឹងកិច្ចការសត្រូវទៅបោះបន្ទាយនៅឯជើងភ្នំ ក៏មកប្រាប់ស្ដេចរបស់ខ្លួនថា "បពិត្រព្រះអង្គ ស្ដេចក្ងោកបានលើកក្បួនព្យុះហយាត្រា ទ័ពទៅបោះបន្ទាយនៅជើងភ្នំហើយសូមព្រះអង្គមានបញ្ជាឱ្យទៅបំផ្លាញទ័ពនោះឱ្យឆាប់ទៅ។ ពេលនោះមន្ត្រីស្ដេចហង្សបានប្រាប់ស្ដេចហង្សថាសត្រូវបានបញ្ជូនចារបុរសគេឱ្យមកធ្វើការសម្ងាត់នៅបន្ទាយយើងហើយ។ ពេលនោះស្ដេចប្រវឹកបានរំលឹកស្ដេចហង្សថា ចារបុរសនោះគឺជាក្អែកស្ដេចហង្សពុំជឿឡើយ ព្រោះស្ដេចហង្សយល់ថាបើចារបុរសមែនហេតុអ្វីវាហ៊ានស្ទុះមកទៅសម្លាប់សេកបែបនេះហើយមួយទៀតការប្រកាសសង្គ្រាមនេះ ទើបតែកើតឡើងពីពេលដែរសត្វសេកមកទេតើ ឯក្អែកមកទីនេះយូរយាណាស់មកហើយ។ តែប្រវឹកបានឆ្លើយកាត់មកថាកុំទុកចិត្តអ្នកបរទេសពេកតែហង្សជំទាស់ថា ជួនកាលអ្នកបរទេសនោះមានប្រយោជន៍ដល់យើងដែរ ស្ដេចហង្សបញ្ជាក់ថែមទៀតថា បើគ្រាន់តែអ្នកបរទេសសុទ្ធតែជាសត្រូវ

ទាំងអស់ឬអ្វី? ក្នុងពួកអ្នកបរទេសទាំងមានខ្លះល្អ ខ្លះអាក្រក់ ខ្លះទៀតនៅកណ្តាលដូចគ្នានឹងអ្នកនៅក្នុងស្រុកដែល។ ប្រវឹកពោលពាក្យទៅកាន់ស្តេចហង្សជាច្រើនតែស្តេចហង្សរករឿងពោលជំទាស់ប្រវឹក លើកទ័ពចេញច្បាំងនឹងទ័ពក្ងោកតែប្រវឹកបាននិយាយប្រាប់ស្តេចហង្សថាខ្លួនបានឮចារបុរសថាស្តេចក្ងោកមិនស្តាប់ពាក្យត្មាតទេ ដូច្នោះស្តេចក្ងោកជាមនុស្សល្ងង់យើងមានផ្លូវយកជ័យជម្នះហើយ ដរាបណាសត្រូវមិនទាន់រំលោយបន្ទាយសត្រូវយើងបានទេនោះយើហនឹងបញ្ចូលសេនាបតីទាំងឡាយមានក្រសាជាដើម ដើម្បីកម្ចាត់ទ័ពសត្រូវដែលកាន់បន្ទាយនៅស្ទឹងទន្លេ ភ្នំ ព្រៃនិងផ្លូវទាំងឡាយជាមុនសិបនអាស្រ័យហេតុនេះ គួរឱ្យក្រសានិងសត្វដទៃទៀតលើកទ័ពទៅបំផ្លាញសត្រូវហើយសម្លាប់ទាំងយប់ទាំងថ្ងៃកុំឱ្យសេសសល់។ ស្តេចហង្សប្រតិបត្តិតាមពាក្យប្រវឹកគ្រប់ប្រការកាលនោះប្រវឹកបាត់បង់ទ័ពសេនាបតីជាច្រើន ហើយកើយទុកក៏និយាយក៏ទៅនិយាយទៅកាន់សត្វត្មាតថា "ម្នាលត្មាត! ម្តេចក៏ឯងធ្វើប្រងើយកណ្តើយនឹកយើង ឬក៏យើងមិនមានវិន័យដូចម្តេចខ្លះ? ពេលនៅត្មានបាននិយាយនិងជួយរកយុទ្ធសាស្ត្រក្នុងការធ្វើសង្គ្រាម ព្រមទាំងនិយាយបន្តទៀតថាព្រះអង្គឃើញទ័ពមានកម្លាំងមានសេចក្តីប្រឹងប្រែងហើយប្រញាប់ធ្វើអង់អាចតែម្យ៉ាងឥតពិចារណាមើលងាយពាក្យណែនាំមន្ត្រីទាំងឡាយដែលដាស់តឿនស្មារតីដោយពាក្យជូរចត់មិនជាទីពេញចិត្តហេតុនេះហើយបានជាព្រះអង្គទទួលផលអាក្រក់នៃការដើរផ្លូវខុសនេះឯងហើយត្មាតក៏បាននិយាយតទៀតថា ទូលបង្គំនឹងលើកទ័ពព្រះអង្គយាត្រាចេញទៅដើម្បីរំលោយបន្ទាយសត្រូវពេលឥឡូវនេះ មិនយូរប៉ុន្មាននឹងនាំព្រះអង្គទៅកាន់ភ្នំរបស់យើងវិញដោយកិត្តិយស និងតេជានុភាពដោយខ្ពង់ខ្ពស់យ៉ាងក្រៃលែង ពេលនោះស្តេចក្ងោកសួរត្មាតថា តើយើងអាចទៅតស៊ូទៀតម្តេចកើត បើទ័ពយើងតិចដូច្នេះត្មាតឆ្លើយដោយអង់អាចថាគេអាចនឹងសម្រេចបានគ្រប់ប្រការព្រោះថាអ្នកដោគជ័យតែងយកការឆាប់ប្រយុទ្ធគឺមិនឱ្យយូរកន្លងពេលវេលា នេះជាលក្ខណៈការយកជ័យឱ្យសម្រេចបានឥតសង្ស័យឡើយព្រោះហេតុនេះត្រូវវាយលុកបន្ទាយសត្រូវឱ្យឆាប់រហ័សចាប់ពីពេលបេះទៅ។ ចំណែកឯសត្វក្រសារចារបុរសស្តេចហង្សក៏ត្រឡប់មករាយការណ៍ប្រាប់ស្តេចហង្សថាស្តេចក្ងោកបង្គាប់ឱ្យលើកទ័ពដែលសល់ឱ្យចូលវាយបន្ទាយយើង តាមការណែនាំរបស់សត្វត្មាតហើយ ពេលនោះហង្សបានរកប្រវឹកសួរថា "នែ៎ ឥឡូវនេះយើងគិតធ្វើដូចម្តេច ប្រវឹកឆ្លើយថា សូមទ្រង់ពិចារណាមើលទ័ពណាមានប្រយោជន៍ ទ័ពណាឥតប្រយោជន៍ឱ្យស្គាល់ច្បាស់លាស់ លុះស្គាល់ទ័ពច្បាស់លាស់ហើយសូមប្រទានរង្វាន់មានមាសប្រាក់សំពត់ខោអាវជាដើម តាមគុណសម្បត្តិដើម្បីរក្សាទឹកចិត្តទ័ព។ ស្តេចហង្សសួរថាការចាយវាយបែបណាទៅទើបសមគួរព្រោះលោកពោលថា "បុគ្គលគួររក្សាទ្រព្យទុកដើម្បីការពារអន្តរាយ"។ សត្វប្រវឹកឆ្លើយថា បុគ្គលដែលមានសេរីសួស្តីតើនឹងកើតមានអន្តរាយមកពីណា ស្តេចហង្សពោលតបថា "ទ្រព្យសម្បត្តិជួនកាលក៏វិនាសខ្លះដែរ"។ ប្រវឹកឆ្លើយថា ឯទ្រព្យសម្បត្តិកដែលសន្សំទុកហើយក៏វិនាសអស់សាបសូន្យវិញដែរបើដូច្នេះសូមព្រះអង្គតាំងចិត្តលះបង់ក្តីកំណាញ់ចោលឱ្យស្រឡះទៅហើយចាយវាយទ្រព្យឱ្យជារង្វាន់និងឱ្យជាយសស័ក្តិ ដល់ទ័ពដែលក្លាហាន ដើម្បីឱអ្នកបម្រើព្រះអង្គបានទទួលនូវសេចក្តីពេញចិត្ត។ ហើយប្រវឹកនិយាយទៅកាន់ស្តេចហង្ស ឱ្យហៅអាមាត្យមកព្រឹក្សា។ ខណៈនោះក្អែកចូលទៅដល់ហើយក្រាបបង្គំទូលថា បពិត្រព្រះអង្គមេត្តាប្រោស ឥឡូវនេះស្តេចក្ងោកជាសត្រូវបានលើកទ័ពមកចោមរោមបន្ទាយយើងហើយ បើទ្រង់មានបញ្ជាបង្គាប់នោះ ទូលបង្គំនឹងចេញទ័ពឥឡូវនេះ ដើម្បីតស៊ូសម្តែងរិទ្ធថ្វីដៃដ៏ក្លាហានឱ្យឃើញប្រាកដជាកិច្ចតបស្នងសងគុណដល់ព្រះអង្គ។ ប្រវឹកស្រែកទេៗ ចេញទៅមិនបានទេបើយើងចេញតស៊ូតើបន្ទាយដែលជាកន្លែងការពារយើងនោះមានប្រយោជន៍អ្វី ព្រះអង្គសូមចេញទៅពិនិត្យមើលគ្រានោះស្តេចហង្សលើទ័ពចេញទៅតាំងនៅមាត់បន្ទាយធ្វើ

សង្គ្រាមដោយក្តីក្លាហាន។ លុះព្រឹកឡើងស្តេចក្ងោកសួរទៅត្មាតថា នែ៎លោកមន្ត្រីជាទីស្រឡាញ់ ចូលលោកចាត់ការតាមគំនិតដែលមានប្តេជ្ញាពីកាលមុនចុះ។ ត្មាតឆ្លើយថា ព្រះអង្គសូមទ្រង់សណ្តាប់ ក្នុងពេលនេះត្រូវបញ្ចេញសេចក្តីប្រឹងប្រែឱ្យអស់ពីទំហឹងតាមកម្លាំង ដែលអាចធ្វើបាន និយាយដូច្នោះហើយត្មាតឱនទៅខ្សឹបត្រជាកក្ងោកថា យើងនឹងធ្វើយ៉ាងនេះ។ កាលព្រះអាទិត្យមិនរះឡើងនោះសង្គ្រាមដ៏សាហាវកំពុងតែប្រយុទ្ធគ្នាក្នុងបន្ទាយទាំង៤ ឯពលក្អែកទាំអឡាយក៏យកភ្លើងទៅដុតក្នុងបន្ទាយ ខណៈនោះឮសម្រែករំពងថាបន្ទាយបែកហើយៗ លុះឮសម្រែកច្រួលច្របល់មើលទៅឃើញឆេះសន្ធោសន្ធៅគ្រប់កន្លែង ស្តេចហង្សព្រមទាំងទ័ពទាំងឡាយដែលនៅក្នុងបន្ទាយទាំងប៉ុន្មានច្រួលច្របល់គ្នាប្រញាប់ប្រញាល់រត់ធ្លាក់ទឹកទាំងអស់។ កាលនោះស្តេចហង្សមានដំណើរយឺតៗតាមសភាពដំណើររបស់ខ្លួនព្រោះធ្លាប់មាននិស្ស័យសោយសុខរត់ចេញទៅឥតមានអ្នកណាហែរហមមានតែក្រសាសេនាបតីជាគ្នាតែប៉ុណ្ណោះ ភ្លាមនោះសត្វមាន់ដែលជាសេនាបតីចូលមកឡោមព័ទ្ធបិទផ្លូវជិត គ្រានោះដែលស្តេចហង្សពោលទៅសត្វក្រសាភ្លាមថាលោកសេនាបតីលោកកុំនៅឱ្យគេសម្លាប់ព្រោះតែលោកមានភក្តីចំពោះយើងតែអ្វីពេលនេះលោកនៅមានពេលអាចរត់គេចមានតើរត់ទៅ! មុជចុះទៅក្នុងទឹកហើយរក្សាខ្លួនឱ្យបានសុខកាលលោករួចខ្លួនហើយ ចុះលើកយកកូនយើងឱ្យឡើងសោយរាជ្យជំនួសយើងនិងស្នើរមតិប្រឹកឱ្យយល់ព្រមផងឯសត្វក្រសានិយាយថាព្រះអង្គសូមកុំមានបន្ទូលយ៉ាងនេះពាក្យព្រះអង្គធ្វើឱ្យទូលបង្គំតឹងទ្រូងណាស់ដរាបណាព្រះច័ន្ទនិងព្រះអាទិត្យនៅមានពន្លឺដរាបនោះសូមឱ្យទ្រង់មានជ័យជម្នះព្រះអង្គទូលបង្គំជាសេនាបតីត្រួតត្រាការពារបន្ទាយ បើសត្រូវចូលមកបាន លុះត្រាតែទ្វាបន្ទាយប្រឡាក់ក្រហមប្រាលដោយឈាមនិងសាច់ទូលបង្គំ គ្រានោះដែរសត្វមាន់ក៏ស្ទុះចូលទៅប្រាស់ស្តេចហង្សដោយខ្នាយរឹងក្រៃលែងរបស់ខ្លួន ខណៈនោះក្រសាស្ទុះចូលទៅរាំងការពារស្តេច ទុកជាមាន់ចឹកដោយជំពុះស្រួចចាក់ដោយខ្នាយមុតស្រួច ដាច់សាច់ឈាមហូរក៏ក្រសានៅតែយកខ្លួនការពារស្តេចហង្សជាដរាប ទីបំផុតស្តេចហង្សចុះទឹកបាន ចំណែកខ្លួនចឹកមានប់ឱ្យស្លាប់ក្នុងពេលនោះដែរ កងពលមាន់ព្រួតគ្នាចឹកសម្លាប់ក្រសារដល់កាលមរណៈទៅហោង រីឯស្តេចក្ងោក បានឱ្យទ័ពប្រមូលទ្រព្យសម្បត្តិក្នុងបន្ទាយហើយត្រឡប់ទៅកាន់បន្ទាយខ្លួន ឮតែសូរសព្ទហូរសសើរថា ជ័យយោ! ជ័យយោគឹងកងរំពងផែនដី។

*( ចប់រឿងហង្ស និងក្ងោក)*

ក្រោយពីបានសណ្តាប់រឿងសង្គ្រាមចប់ហើយព្រះរាជបុត្រក៏មានបន្ទូលគ្រប់ព្រះអង្គថា "យើងគ្រប់គ្នា មានសេចក្តីត្រេកអរក្រៃលែងដោយបានស្តាប់រឿងនេះ"។ លោកមហាបណ្ឌិតទូលតទៅទៀតថា៖ "សូមទ្រង់ទាំងឡាយព្រះសណ្តាប់ស្លោកទីបំផុតនេះថែមទៀត"

១៤៩.សូមព្រះរាជបុត្រទាំងឡាយកុំឱ្យជួបប្រទះសឹកសង្គ្រាមដែលប្រកបដោយពលដំរី សេះ និងកងទ័ពទាំងឡាយ ដូច្នេះឡើយសូមឱ្យស្តេចនៃពួកសត្រូវបាក់បបខ្លបខ្លាចបារមីដោយគ្រាប់តែខ្យល់គឺព្រះរាជនយោបាយ ហើយរត់ ខ្វាត់ខ្វាយទៅពួនលាក់ខ្លួននៅនាព្រៃភ្នំក្រំថ្មវិនាសគ្រប់កាលវេលាទៅហោង។

កថាទី៣ ឈ្មោះសង្គ្រាមដែលមានក្នុងហិតោបទេសចប់តែប៉ុណ្ណោះ។

I. **វិភាគអត្ថន័យរឿង**

\+ **ប្រធានរឿង៖** ការធ្វើសង្គ្រាមរវាងស្ដេចហង្ស និងស្ដេចក្ងោកក្នុងការដណ្ដើមឥទ្ធិពលដរាប គ្រប់គ្រងប្រទេស។

\+ **មូលបញ្ហារឿង**

- បញ្ហាទី១៖ ទំនាស់រវាងសត្វកុក និងបរិវារស្ដេចក្ងោក។ គឺកើតឡើងដោយសារកុកហើររកចំណីនៅដែនដីក្ងោក ជាទឹកដីស្ដេចក្ងោកគ្រប់គ្រង។
- បញ្ហាទី២៖ សង្គ្រាមដណ្ដើមដរាបនៃការពង្រីកឥទ្ធិពលគ្រប់គ្រងទឹកដីហង្ស និងក្ងោក។
- បញ្ហាទី៣៖ ដំណោះស្រាយដោយការធ្វើសង្គ្រាបប្រកបដោយយុទ្ធសាស្ត្រល្អៗនៃភាគីស្ដេចហង្សនិង្សស្ដេចក្ងោក។

\+ **ឧត្តមគតិរឿង**

- អប់រំមនុស្សត្រូវដាក់ខ្លួន និងសម្របខ្លួនជាមួយអ្នកដទៃ
- អប់រំកុំឱ្យអួតហួសសមត្ថភាពខ្លួន
- អប់រំឱ្យចេះគិតពិចារណាមុនធ្វើកិច្ចការអ្វីមួយ
- អប់រំឱ្យចេះមានភក្ដីភាពចំពោះជាតិ
- អប់រំឱ្យចេះពិភាក្សាគ្នាមុនធ្វើអ្វីមួយ
- អប់រំកុំឱ្យជឿទុកចិត្តអ្នកដៃ
- អប់រំឱ្យចេះដោះស្រាយសន្តិវិធីតាមការទូត
- អប់រំឱ្យដឹកគុណអ្នកដទៃ
- អប់រំឱ្យប្រុងប្រយ័ត្នចំពោះជនដែលមិនទាន់ស្គាល់ច្បាស់
- ...

\+ **វិភាគតួអង្គ**

➢ **ស្ដេចហង្ស**

\+ **គុណសម្បត្តិ**

- ជាស្ដេចដែលមានរិទ្ធិដរាបត្រូវបានតែងតាំងដោយសត្វទាំងឡាយឱ្យឡើងធ្វើស្ដេច
- ជាស្ដេចដែលអង់អាចក្លាហានក្នុងការធ្វើសង្គ្រាមដើម្បីការពារប្រទេសរបស់ខ្លួន

– ជាស្តេចដែលចេះស្តាប់មតិយោបល់របស់រដ្ឋមន្ត្រី

– ជាស្តេចចេះដឹងគុណចំពោះអ្នកដែលជួយខ្លួន

– ...

+ **គុណវិបត្តិ**

– ជាមនុស្សឆាប់ជឿគេដោយមិនបានគិតវិភាគច្បាស់លាស់

– គ្មានសមត្ថភាពការពារប្រទេសជាតិ

– ...

➢ **ស្តេចក្អែក**

+ **គុណសម្បត្តិ**

– ជាស្តេចដែលមានភាពអង់អាចក្នុងការធ្វើសង្គ្រាម

– ជាស្តេចដែលមានពលទ័ពច្រើន

– ដឹកកំហុសនិងចេះកែប្រែខ្លួន

– យកភាពជ័យជម្នះជូនប្រទេស

– ...

+ គុណវិបត្តិ

– ក្រេវក្រោធជាមួយនឹងមន្ត្រីដែលជួយណែនាំ

– មិនមានការគិតពិចារណាឱ្យបានល្អិតល្អន់លើបញ្ហា

– ពុំដោះស្រាយបញ្ហាដោយសន្តិវិធី

– ...

➢ **រដ្ឋមន្ត្រីប្រវឹក**

+ **គុណសម្បត្តិ**

– ជាមន្ត្រីដែលមានចំណេះដឹងខ្ពង់ខ្ពស់

– ជាមន្ត្រីដែលមានគុណធម៌ និងសីលធម៌

- ចេះដោះស្រាយបញ្ហាដោយសន្តិវិធី
- មានចិត្តស្មោះត្រង់នឹងស្តេច
- ចេះប្រើប្រាស់ភាសាការទូត
- ចេះប្រឹក្សាមតិល្អៗជាមួយស្តេច
- ...

+ **គុណវិបត្តិ**

- បណ្តោយឱ្យស្តេចចេញសង្គ្រាមដោយផ្ទាល់
- ...

➢ **រដ្ឋមន្ត្រីត្មាត**

+ **គុណសម្បត្តិ**

- មានចំណេះដឹងខ្ពង់ខ្ពស់
- យល់ការរាក់ជ្រៅ
- ដាស់តឿនស្តេចក្ងោកជាដរាប
- ចេះក្បួនសឹកសង្គ្រាម
- ចេញធ្វើសឹកសង្គ្រាមដោយផ្ទាល់
- ...

+ **គុណវិបត្តិ**

- ពុំធ្វើសកម្មភាពក្នុងពេលដែលទ័ពត្រូវគេសម្លាប់ច្រើន
- ....

➢ **ក្រសា**

- ជាសេនាដែលមានភាពអង់អាចក្លាយហាន មោះមុតមិនខ្លាចស្លាប់
- ហ៊ានយកជីវិតការពារស្តេច
- មានភាពភក្តីភាពស្មោះត្រង់នឹងម្ចាស់

- ហ៊ានពលីដើម្បីជាតិ
- តស៊ូដល់ដង្ហើមចុងក្រោយ
- ...

➢ **សត្វកុក**

+ **គុណសម្បត្តិ**

- ក្លាហានចេះដោះស្រាយបញ្ហាចំពោះមុខ
- ស្រឡាញ់ស្តេច និងឱ្យតម្លៃការគ្រប់គ្រាងរបស់ស្តេច
- ស្រឡាញ់ទឹកដីរបស់ខ្លួន
- ស្តាប់តាមការបញ្ជារបស់ស្តេច

+ **គុណវិបត្តិ**

- ជាសត្វចូរចិត្តអួតអាង
- មិនចេះគិតពិចារណា
- ដោះស្រាយបញ្ហាដោយហឹង្សា
- ហ៊ានអាកាត់រឿងប្រទេសជាតិទាំងមូលដោយភាពឆោតល្ងង់
- ...

➢ **សត្វសេក**

- គោរពតាមតួនាទីជាការទូត
- ចេះគិតពិចារណា
- មានចំណេះដឹង
- មានសីលធម៌ក្នុងការនិយាយស្តី
- ស្មោះត្រង់និងស្តេច
- ...

➢ **សត្វក្អែក**

- មានល្បិចកលខ្ពស់
- លួងលោមបោបញ្ឆោតស្ដេចហង្ស
- ជាជង្គូវក្នុងសាច់ដែលសង្ខំលាក់ខ្លួនក្នុងប្រទេសរបស់ស្ដេចហង្ស
- ...។

**II. វិភាគអត្ថរូប**

នៅក្នុងរឿងស្រីហិតោបទេស អ្នកនិពន្ធមានតាក់តែងឡើងដោយសរសេរជាភាសាសំស្រ្កឹត។

**III. វិភាគអត្ថរស**

- **សោភ័ណរស៖** សាច់រឿងអ្នកនិពន្ធ មាននិទាន និងសុភាសិតជាកាព្យមានរសជាតិផ្អែមល្ហែមចាប់ចិត្តផ្ដើម។
- **តថរស៖** ដំណើររឿងឆ្លុះបញ្ចាំងពីសកម្មភាពពិតនៃការគ្រប់គ្រងប្រទេសដោយដរាបស្ដេច និងទំនាស់ដណ្ដើមនៃការពង្រីកឥទ្ធិពលរបស់ស្ដេចនីមួយៗដោយការធ្វើសង្គ្រាម។ ម្យ៉ាងទៀត អ្នកនិពន្ធក៏បានថា ចំណេះដឹង សមត្ថភាព ភាពក្លាហាន តស៊ូ ព្យាយាម នឹងទទួលបាន ជោគជ័យ។
- **សង្គមរស៖** ជាតម្លៃដែលអ្នកនិពន្ធបានលើកឡើយពីរឿងរ៉ាវនៃរបបមួយដែលគ្រប់គ្រង់ដោយស្ដេចផែនដី ដែលមានសត្វហង្សជាស្ដេចដែលនៅដែលដីទឹក និងគោកគ្រប់គ្រងដោយស្ដេចក្ងោក។ ហើយស្ដេចនីមួយៗសុទ្ធសឹងពង្រីកឥទ្ធិពលរបស់ខ្លួនដោយការធ្វើសង្គ្រាម។
- **ទារុណរស៖** ក្រោយពីបញ្ចប់សង្គ្រាម ស្ដេចហង្សត្រូវបាត់បង់ដរាប និងប្រទេសដែលប្រទេសរបស់ខ្លួន ការស្លាប់របស់ពលជាច្រើន។ព្រមទាំងការស្លាប់របស់ក្រសាដោយការគេធ្វើទុករហូតដល់ស្លាប់។
- **កុសលរស៖** រឿងសង្គ្រាមហង្ស និងក្ងោកមានតម្លៃអប់រំ
  - ក្លាហាន ហ៊ានពលីកម្មចំពោះជាតិ
  - ចេះសាមគ្គី
  - ឱ្យចេះដោះស្រាយបញ្ហាដោយអហិង្សាតាមរយៈការទូត
  - ស្មោះត្រង់ចំពោះគ្នានិងគ្នា

– កុំជឿទុកចិត្តអ្នកដទៃដោយពុំបានគិតពិចារណា

– ត្រូវចេះគិតពិចារណាមុននឹងធ្វើកិច្ចការណាមួយ

– ...។

**ជំពូកទី៣**

* **សេចក្តីសន្និដ្ឋាន**

តាមរយៈការសិក្សាយើងឃើញថា ទោះបីជា ស្រីហិតោបទេស មានប្រភពមកពីឥណ្ឌាក៏ដោយក៏រឿងនេះមានអត្ថន័យ និងមានតម្លៃចំពោះវប្បធម៌ជាតិខ្មែរយើងយ៉ាងពិតប្រាកដ។ ទោះបីជាសាច់រឿងមានលក្ខណៈជានិទានសត្វក៏ដោយ ក៏សាច់រឿងមានលក្ខណៈបង្ហាញពីសង្គមមនុស្ស ពោលអ្នកនិពន្ធបញ្ចូលនូវគំនិតអប់រំទស្សនៈល្អៗ សម្រាប់ឱ្យមនុស្សគ្រប់រូបរិះគិតពិចារណា។

* **ឯកសារយោង**

កិច្ចការស្រាវជ្រាវមួយនេះដកស្រង់ចេញពី សៀវភៅសង្ខេបស្រីហិតោបទេស ដែលរៀបចំដោយ ( *បញ្ញាវន្តខ្មែរ និងនិស្សិតមួយក្រុមមានលោក វ៉េត សារ៉ុន លោក រស់ ចាន់ថុល លោក ហេង ទីគា និងមានការផ្តល់មតិយោបល់បន្ថែមពីលោកសាស្ត្រាចារ្យ ហ៊ុន ឈុនតេង បណ្ឌិត ប៉ា ចាន់រឿន និងលោក ឡឹក ជំនោរ ក៏ដូចជាសមាគមន៍អ្នកនិព្វខ្មែរ ដើម្បីសម្រួលដល់ការពិនិត្យជារួម*)។